COUNTY OF LOS ANGELES
Public Health

# សេចក្តីជូនដំណឹង

ថ្ងៃទី 1 ខែមករា ឆ្នាំ 2026

សៀវភៅផ្តល់ព័ត៌មានដល់សមាជិកអំពីសុខភាពផ្នែកអាកប្បកិរិយាប្រចាំខោនធី Los Angeles (Los Angeles County Behavioral Health Member Handbook) គឺបានធ្វើឱ្យថ្មីឡើងវិញ គិតចាប់ពីថ្ងៃទី 1 ខែកុម្ភៈ ឆ្នាំ 2026 តទៅ និងអាចរកបានជាច្រើនភាសាខុសៗគ្នានៅលើ៖ គេហទំព័រផ្តល់ធនធាន និងព័ត៌មានដល់អ្នកទទួលការព្យាបាលផ្នែកការទប់ស្កាត់ និងការគ្រប់គ្រងការប្រើប្រាស់សារធាតុញៀន (Substance Abuse Prevention and Control Patient Resource and Information) តាមរយៈ៖ https://publichealth.lacounty.gov/sapc/PatientPublic

ដើម្បីទទួលបានច្បាប់ចម្លងជាលក្ខណៈបោះពុម្ពដោយមិនគិតថ្លៃ សូមស្នើសុំតាមរយៈអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ហើយអ្នកនឹងទទួលបានមួយច្បាប់ក្នុងអំឡុងពេលប្រាំ (5) ថ្ងៃធ្វើការ (មិនគិតថ្ងៃសៅរ៍ និងថ្ងៃអាទិត្យទេ)។

ការធ្វើឱ្យថ្មីឡើងវិញទាំងឡាយនៅក្នុងសៀវភៅផ្តល់ព័ត៌មានដល់សមាជិកនេះរួមមានផ្នែកផ្សេងៗអំពី ព័ត៌មានបន្ថែមទៀតអំពីខោនធីរបស់អ្នក (Additional Information About Your County) ពាក្យផ្សេងៗដែលត្រូវដឹង (Words to Know) សេចក្តីជូនដំណឹងអំពីការអនុវត្តន៍ក្នុងការរក្សាការសម្ងាត់ (Notice of Privacy Practices) ហើយនិងព័ត៌មានអំពីសេវាកម្មប្រភេទថ្មីៗ (ណាមួយដែលអនុវត្តចំពោះអ្នក) ដូចជា៖

- ការព្យាបាលផ្នែកការប្រាស្រ័យទាក់ទងគ្នារវាងឪពុកម្តាយ និងកូន(Parent-Child Interaction Therapy ឬហៅកាត់ថា PCIT)

- ការព្យាបាលផ្នែកការទំនាក់ទំនងនៅក្នុងគ្រួសារ (Functional Family Therapy ឬហៅកាត់ថា FFT)
- ការព្យាបាលកម្រិតខ្លាំងទាក់ទងទៅនឹងប្រព័ន្ធច្រើនបែបយ៉ាង (Multisystemic Therapy ឬហៅកាត់ថា MST)
- ការព្យាបាលផ្នែកសុខភាពផ្លូវចិត្តកម្រិតធ្ងន់ធ្ងរដោយផ្អែកទៅលើសហគមន៍ (Assertive Community Treatment ឬហៅកាត់ថា ACT)
- ការព្យាបាលផ្នែកសុខភាពផ្លូវចិត្តកម្រិតធ្ងន់ធ្ងរ ហើយទាក់ទងទៅនឹងប្រព័ន្ធយុត្តិធម៌ ដោយផ្អែកទៅលើសហគមន៍ (Forensic Assertive Community Treatment ឬហៅកាត់ថា FACT)
- ការថែទាំជាលក្ខណៈឯកទេសដែលមានការសម្របសម្រួលត្រឹមត្រូវ (Coordinated Specialty Care ឬហៅកាត់ថា CSC) សម្រាប់អ្នកដែលបង្ហាញសញ្ញានៃបញ្ហាផ្លូវចិត្តកម្រិតធ្ងន់ធ្ងរជាលើកដំបូង (First Episode Psychosis)
- សេវាកម្មជំនួយផ្សេងៗពីសហគមន៍ (Clubhouse Services)
- សេវាកម្មដែលកាន់តែប្រសើរឡើងពីអ្នកធ្វើកិច្ចការផ្នែកសុខភាពនៅក្នុងសហគមន៍ (Enhanced Community Health Worker Services)
- ជំនួយផ្នែកកិច្ចការងារ (Supported Employment)
- ការអនុវត្តន៍នានាផ្នែកការថែទាំសុខភាពតាមទំនៀមទម្លាប់ (Traditional Health Care Practices)
- សេវាកម្មផ្សេងៗសម្រាប់អ្នកដែលមិនអាចទទួលជំនួយដោយខ្លួនឯងបាន (In-Reach Services)

ប្រសិនបើអ្នកត្រូវការជំនួយជាភាសារបស់អ្នក ជំនួយឬសេវាកម្មបន្ទាប់បន្សំសម្រាប់ពិការភាពរបស់អ្នក ឬក៏ដើម្បីទទួលបានឯកសារផ្សេងៗជាអក្សរផុសសម្រាប់អ្នកពិការភ្នែក (braille) ឬជាអក្សរពុម្ពធំៗនោះ ចំណុចទាំងនេះគឺអាចរកបានតាមការស្នើសុំ ដោយការទូរស័ព្ទទៅកាន់លេខ 1-800-854-7771 (លេខសម្រាប់អ្នកថ្លង់ [TTY]៖ 711)។ សេវាកម្មទាំងនេះគឺមិនគិតថ្លៃនោះទេ។

(Cambodian)